# រឿង

# ជនញ៉ម



ស្របតាមកម្មវិធីសិក្សា

# ធនញ្ជ័យ

នេះនឹងនិយាយពីរឿងធនញ្ជ័យ កាលដើមឡើយមកចាប់កំណើត ក្នុងពោះនាងម្ដាយ នាងម្ដាយយល់សប្ដិទៀបឯព្រឹកដូចជាយល់សូង យល់សប្ដិ បេះដូងបេះបានទាំងផ្ទៃ យល់សប្ដិឃើញខែ ខែនោះពេញបូណ៌មី។ នាងនោះ ភ្ញាក់ឡើងពីដេកគិតថា សប្ដិនេះល្អណាស់ បើដូច្នេះអញនឹងទៅអោយហោរ មើលអោយបានដឹងថាសប្ដិនេះល្អឬអាក្រក់អោយប្រាកដៗ គិតស្រេចក៏យកទៀន ធូបទៅដល់ផ្ទះហោរ អ្នកហោរមិននៅ នៅតែប្រពន្ធ នាងនោះទៅដល់ផ្ទះហោរ ហើយសួរថា អ្នកហោរនៅទេ ប្រពន្ធហោរប្រាប់ថាមិននៅទេ រកគាត់ថ្វីនាង នាងនៅប្រាប់ថា មករកគាត់អោយទាយសប្ដិ ត្បិតខ្ញុំដេកលក់ទៅយល់សប្ដិទៀប ឯព្រឹកហាក់ដូចយល់សូង យល់សប្ដិឡើងបេះដូងបេះបានទាំងផ្ទៃ យល់សប្ដិ ឃើញខែៗពេញបូណ៌មី ប្រពន្ធហោរស្ដាប់ដឹងសព្វគ្រប់ដឹងថានាងនោះនឹងកើត កូន កូននោះប្រុសនឹងបានជាស្ដេច ដឹងដូច្នេះក៏នឹកច្រណែនហើយគិតថា អញ នឹងទាយអោយទៅជាខ្ញុំគេ គិតស្រេចហើយប្រាប់ថា នាងនឹងមានកូនប្រុសមួយ នឹងទៅជាខ្ញុំគេ នាងនោះស្ដាប់ប្រពន្ធហោរទាយដូច្នោះហើយក៏លាវិលមកផ្ទះវិញ។ ដល់ពេលសំរាល កូននោះជាប្រុសមែន ម៉ែឪហៅឈ្មោះថាធនញ្ជ័យ បានអាយុ ៧ឆ្នាំក្មេងនោះដើរទៅលេងផ្ទះមហាសេដ្ឋីដែលនៅជិតខាងដោយសព្វៗថ្ងៃ។ ថ្ងៃមួយ ប្រពន្ធមហាសេដ្ឋីត្បាញនៅលើផ្ទះ បោះត្រល់ទៅវាធ្លាក់ទៅដី ក្រលេកទៅឃើញ ធនញ្ជ័យលេងនៅនោះក៏ស្រែកថា អាជ័យអើយរើសត្រល់អោយអញ ធនញ្ជ័យ សួរវិញថា បើខ្ញុំរើសត្រល់ តើអោយរបស់អ្វីខ្ញុំ ប្រពន្ធមហាសេដ្ឋីថា អញអោយ អំបុកអាជ័យឯង ធនញ្ជ័យសួរទៀតថា តើអោយតិចឬច្រើន នាងប្រពន្ធមហា សេដ្ឋីប្រាប់ថា អញអោយច្រើន ទើបធនញ្ជ័យរើសត្រល់អោយ ហើយអង្គុយចាំ

ទារអំបុកពីប្រពន្ធមហាសេដ្ឋីថា អោយអំបុកមក ខ្ញុំនឹងអាលទៅផ្ទះ ប្រពន្ធមហាសេដ្ឋីអោយអំបុកមកធនញ្ជ័យ ធនញ្ជ័យ ថាថាតិចណាស់ អោយច្រើនទៀត ទើបប្រពន្ធមហាសេដ្ឋីអោយយកអំបុកមកអោយធនញ្ជ័យច្រើនដល់ទៅមួយកញ្ជើរ ធនញ្ជ័យនៅតែទារថាអោយច្រើនទៀត ប្រពន្ធមហាសេដ្ឋីថា អញអោយច្រើនអស់ប៉ុណ្ណឹងហើយ ធនញ្ជ័យស្តាប់ហើយខឹងយំទារតែអំបុកច្រើនៗនោះ ឮដល់មហាសេដ្ឋី មហាសេដ្ឋីដើរចូលមកមើលហើយសួរថា អាជ័យថ្វីក៏យំ ទើបប្រពន្ធមហាសេដ្ឋីប្រាប់ថា ខ្ញុំអោយវារើសត្រល់អោយ ខ្ញុំថាអោយអំបុកវាច្រើន ឥឡូវខ្ញុំអោយវាដល់មួយកញ្ជើរទៅហើយ វានៅតែទារថាអោយច្រើនទៀត ឥឡូវនេះវាអង្គុយតែយំ មហាសេដ្ឋីក៏ថា ឱឯងមិនដឹងចិត្តអាជ័យទេ មានតែអញអោយវាទើបវាព្រមសុខចិត្ត ទើបមហាសេដ្ឋីហៅថា អាជ័យមកណេះអញអោយអំបុកឯងច្រើន ឯធនញ្ជ័យឮមហាសេដ្ឋីហៅដូច្នោះហើយក៏ដើរទៅតាមមហាសេដ្ឋី មហាសេដ្ឋីអោយយកចង្អេរមួយមកដាក់អំបុកនឹងចង្អេរអោយបានជាពីរចំណែកហើយសួរថា អាជ័យអាមើល អំបុកណាច្រើន ធនញ្ជ័យចង្អុលទៅអំបុកនឹងចង្អេរថា នេះច្រើន ចង្អុលទៅអំបុកនឹងចង្អេរថា នេះតិច ទើបមហាសេដ្ឋីថា បើឯណាច្រើនអាឯងយកខាងច្រើននោះចុះ ធនញ្ជ័យយកអំបុកនឹងចង្អេរ ពេលកើបអំបុកហើយទើបគិតក្នុងចិត្តថា ឱអញចាញ់បោកមហាសេដ្ឋីនេះហើយ អញនឹងផ្ចាញ់ប្រាជ្ញាគាត់នេះអោយបានទើបអញសុខចិត្ត។ ធនញ្ជ័យ គិតដូច្នេះស្រេចហើយ ដើរទៅដល់ម្តាយឪពុកក៏ប្រាប់ម្តាយថា អ្នកម៉ែទៅយកប្រាក់សេដ្ឋី ខ្ញុំនឹងជាខ្ញុំមហាសេដ្ឋីនឹងបំរើលោកតាមចិត្តខ្ញុំប៉ង ខ្ញុំមិននៅនឹងអ្នកម៉ែទេ។ ម្តាយធនញ្ជ័យឮកូនថាដូច្នោះហើយសួរកូនថា អ្នកមាសម្តាយ ម្តាយនឹងមានជំពាក់បំណុលគេក៏ទេ ម្តេចក៏អោយម្តាយយកកូនទៅនៅជាខ្ញុំគេដូច្នោះ ទើបធនញ្ជ័យប្រាប់ម្តាយថា ខ្ញុំនឹងទៅនៅផ្ចាញ់ប្រាជ្ញាលោកមហាសេដ្ឋីទេ ម្តាយឪពុកឃាត់កូនមិនបានក៏អោយកូនទៅនៅជាខ្ញុំមហាសេដ្ឋីអំពីថ្ងៃនោះឯង។

មហាសេដ្ឋីក៏ប្រើចៅធនញ្ជ័យអោយកាន់ថាសស្លាដើរតាមទៅគាល់ស្តេចសព្វៗថ្ងៃទៅ ឯធនញ្ជ័យដើរក្រដល់ ត្បិតមហាសេដ្ឋីជិះសេះនឹងដើរមិនទាន់ បានជាមហាសេដ្ឋីស្រដីថា អាជ័យឯងដើរដូចម្តេចក៏មិនទាន់អញ ទើបធនញ្ជ័យប្រាប់ថាត្បិតខ្ញុំបាទខ្លាចវាជ្រុះប្រអប់អំពីថាសស្លា មហាសេដ្ឋីស្រដីប្រាប់ថាអំពីថ្ងៃនេះទៅអាឯងត្រូវរត់អោយទាន់សេះអញ ធនញ្ជ័យស្តាប់ហើយ ឆ្លើយថាបាទៗ

លុះដល់ថ្ងៃក្រោយមក ធនញ្ជ័យត្រូវចេញទៅតាមមហាសេដ្ឋីទៀត កាលមហាសេដ្ឋីឡើងជិះសេះចេញទៅ ធនញ្ជ័យពឹតតែរត់តាមក្រោយសេះជ្រុះអស់ប្រអប់ស្លាអំពីក្នុងថង់ស្រេះ នៅតែថាសស្លាហើយនិងថង់ស្រេះទទេ លុះទៅដល់សាលាជំនុំមហាសេដ្ឋីចុះអំពីខ្នងសេះឡើងទៅលើសាលាជួបជុំអង្គុយនឹងអស់នាម៉ឺនធំតូចហើយក៏ហៅទៅថា អាជ័យយកស្លាមកអោយអញស៊ី ឯធនញ្ជ័យយកថាសស្លាជូនមហាសេដ្ឋី ហើយថយមកអង្គុយនៅទីមួយដ៏គួរសមនឹងខ្លួនឯង មហាសេដ្ឋីទទួលថាសស្លាយកមក មើលទៅឃើញតែថាសទទេ ខ្មាសគេមិនហ៊ានស្រដីថាអ្វីៗឡើយ លុះដល់ពេលត្រលប់មកផ្ទះវិញក៏ហៅថា អាជ័យអាមកណេះ ឯធនញ្ជ័យឮមហាសេដ្ឋីហៅខ្លួនដូច្នោះហើយក៏ដើរចូលទៅ មហាសេដ្ឋីក៏សួរថា អាជ័យ តើប្រអប់ស្លាអញបាត់អស់ទៅណា ធនញ្ជ័យឆ្លើយថាវាជ្រុះតាមផ្លូវ មហាសេដ្ឋីខឹងណាស់ស្រែកថា អាឯងដូចម្តេចក៏ជ្រុះធ្លាក់របស់អស់មិនរើសឡើងវិញ ធនញ្ជ័យជំរាបថាខ្ញុំបាទខ្លាចតាមមិនទាន់លោកតាបានជាបាទមិនហ៊ានឈប់រើស ត្បិតលោកតាផ្តាំថាអោយរត់អោយទាន់សេះលោកតានោះឯង មហាសេដ្ឋីក៏ប្រាប់ថា បើទៅលើកក្រោយ ជ្រុះរបស់អ្វីអោយរើសកុំខាន បើមិនបានរើស អញវាយអាឯង ធនញ្ជ័យស្តាប់ឮមហាសេដ្ឋីផ្តាំដូច្នោះហើយក៏ចាំទុកៗ

ព្រឹកស្អែកឡើងមហាសេដ្ឋីត្រូវទៅគាល់ស្តេចជាថ្មីទៀត គាត់ឡើងជិះសេះ ឯធនញ្ជ័យកាន់ថាសស្លារត់តាមក្រោយសេះនោះឯង លុះដល់សេះវាជុះអាចម៍ ធនញ្ជ័យក៏រើសអាចម៍សេះដាក់ក្នុងថង់ស្លាទាល់តែពេញហើយរត់តាមក្រោយទៅ

មហាសេដ្ឋីជិះសេះទៅដល់មុន រកមើលធនញ្ជ័យមិនឃើញ លុះធនញ្ជ័យទៅដល់ ក៏សួរថា មើលអាឯងថ្វីក៏ដើរមិនអោយទាន់អញ ទើបធនញ្ជ័យជំរាបថា បានជាខ្ញុំបាទតាមមិនទាន់លោកតា ត្បិតខ្ញុំបាទរវល់ឈប់រើសអាចម៍សេះវាធ្លាក់ច្រើនណាស់ ត្បិតប្រសាសន៍លោកតាផ្តាំថា បើមានរបស់អ្វីជ្រុះអោយខ្ញុំបាទឈប់រើសទាំងអស់ ដូច្នេះហើយបានជាយូរៗ មហាសេដ្ឋីថា អាឯងអោយថាសស្លាមកអញ ធនញ្ជ័យប្រគល់ថាសស្លាចេញទៅ មហាសេដ្ឋីមើលឃើញសុទ្ធតែអាចម៍សេះនៅក្នុងថង់ស្រេះក៏អៀនខ្មាសអស់នាម៉ឺនដែលអង្គុយនៅលើសាលាជាមួយគ្នា គាត់មិនស្រដីថាអ្វីៗឡើយ ហើយក៏ចុះពីសាលាឡើងសេះបរទៅផ្ទះវិញ ឯធនញ្ជ័យក៏យកថាសស្លាមកហើយដើរទៅតាមមហាសេដ្ឋី លុះទៅដល់ផ្ទះ មហាសេដ្ឋីស្រដីថា អាជ័យឯងកុំតាមអញទៅគាល់ឡើយ អាឯងសមតែចាំចំការវិញ ទើបសមនឹងមុខងារអាឯង រួចមហាសេដ្ឋីប្រាប់ថា តាំងតែពីថ្ងៃនេះទៅ អាឯងទៅចាំចំការតែសព្វៗថ្ងៃទៅ ឯធនញ្ជ័យស្តាប់ហើយក៏ឆ្លើយថាបាទ ហើយក៏ដើរចេញទៅចាំចំការដូចដែលមហាសេដ្ឋីប្រើដូច្នោះឯង។

ធនញ្ជ័យដេកចាំចំការ ឯអស់ដំណាំនៅក្នុងចំការនោះសត្វគោក្របីវាស៊ីអស់នឹងមានដេញក៏ទេ លុះដល់មហាសេដ្ឋីដើរទៅមើលចំការក៏មិនឃើញមានសល់ដំណាំអ្វីឡើយ ឃើញតែគោក្របីកំពុងស៊ីឥតសំចៃ ក៏ស្រែកហៅថា អាជ័យអើយអាមកណោះអញនឹងសួរអាឯងមើល ធនញ្ជ័យឮហើយក៏ដើរចូលទៅរកហើយក្រាបសំពះនៅមុខមហាសេដ្ឋី នៅស្ងៀមចាំស្តាប់មហាសេដ្ឋីនឹងថាដូចម្តេច។ មហាសេដ្ឋីសួរថា អាជ័យ អាឯងរវល់ដើរទៅឯណាទើបមិនដេញគោក្របីអោយវាស៊ីដំណាំអស់ ធនញ្ជ័យឆ្លើយថា បានជាខ្ញុំបាទពុំបានដេញគោក្របីវាស៊ីដំណាំនោះ ត្បិតលោកតាមិនបានផ្តាំអោយដេញគោក្របី លោកតាផ្តាំតែថាអោយខ្ញុំបាទមើលតែចំការ ឥឡូវនេះចំការវានៅតែវាទេ នឹងមានបាត់ទៅណា។ មហាសេដ្ឋីស្តាប់ហើយក៏នៅស្ងៀម នឹកថាអាជ័យនេះហៅពេញជាកាចណាស់

បើដូច្នេះតើនឹងប្រើការអ្វីបាន ទីបំផុតមហាសេដ្ឋីគិតថា មានតែប្រើវាអោយឃ្វាលគោវិញ ទើបមហាសេដ្ឋីហៅថា អាជ័យឯងមកណេះ ធនញ្ជ័យឮហើយឆ្លើយថាបាទ ហើយដើរចូលទៅអង្គុយនៅស្ងៀមនៅមុខមហាសេដ្ឋី ឯមហាសេដ្ឋីក៏ប្រាប់ថាអាជ័យទៅឃ្វាលគោសព្វៗថ្ងៃកុំអោយខានឡើយ ធនញ្ជ័យស្តាប់ហើយក៏ជំរាបសុំមហាសេដ្ឋីថា ត្បិតខ្លួនខ្ញុំបាទឥតមានប្រពន្ធ ឥឡូវនេះលោកតាអោយទៅឃ្វាលគោ ខ្ញុំបាទអរហើយនឹងបានប្រពន្ធច្រើន ខ្ញុំបាទជំរាបថាគោញីទាំងអស់ដែលមានប៉ុន្មាននៅក្នុងរោងនេះ អោយតែឈ្មោះថាគោញី ខ្ញុំបាទសុំយកធ្វើប្រពន្ធទាំងអស់ៗ មហាសេដ្ឋីមិនមានស្រដីថាអ្វី ឯធនញ្ជ័យក៏ជំរាបលាមហាសេដ្ឋីទៅឃ្វាលគោទៅសព្វៗថ្ងៃ ហើយបើមានគោឈ្មោលឯណាវាមកពាក់គោញីនោះធនញ្ជ័យក៏ចោទថាគោឈ្មោលទាំងនោះវាលួចប្រពន្ធខ្លួនហើយចាប់ចងទុកជាច្រើនណាស់ ម្ចាស់គោឈ្មោលគេមកសុំយក ធនញ្ជ័យមិនអោយទេហើយប្រាប់គេថាគោអ្នកឯងមកលួចប្រពន្ធអញ បើចង់បានទៅវិញមានតែយកប្រាក់មកអោយអញទើបអញបើកអោយយកទៅ បើមិនយកប្រាក់មកអោយអញ អញមិនបើកអោយវាទៅទេៗ ម្ចាស់គោឈ្មោលកាលបើបានឮធនញ្ជ័យថាដូច្នោះហើយក៏កើតក្តីក្តៅក្រហាយ ចូលទៅប្តឹងដល់លោកមហាសេដ្ឋីថា សូមជំរាបលោកមហាសេដ្ឋីបានជ្រាប ត្បិតលោកអោយធនញ្ជ័យឃ្វាលគោនោះ វាចាប់គោឈ្មោលយើងខ្ញុំរាល់គ្នាអស់គោ២០ឬ៣០ វាគោនោះទៅលួចប្រពន្ធវា វាថាគោញីទាំងអស់នោះលោកមហាសេដ្ឋីអោយជាប្រពន្ធវា បើដូច្នេះយើងខ្ញុំទាំងអស់គ្នាពុំសុខចិត្តនឹងធនញ្ជ័យវាធ្វើពុំត្រឹមត្រូវ សូមអោយលោកយកគោអោយយើងខ្ញុំវិញៗ ឯមហាសេដ្ឋីស្តាប់ហើយក៏គិតថា អញប្រើអាជ័យនេះនឹងកើតទោសច្រើនទៅទៀត គាត់ប្រើមនុស្សម្នាក់ថា អាឯងទៅហៅអាជ័យហើយយកទាំងគោដែលវាចាប់នោះមកផង បំរើនោះស្តាប់ហើយក៏ដើរទៅហៅធនញ្ជ័យដូចពាក្យមហាសេដ្ឋីប្រើនោះឯង ទៅដល់ហើយប្រាប់ថា ចៅជ័យ ឥឡូវនេះលោកមហាសេដ្ឋីប្រើអញអោយមកហៅ

ចៅជ័យឯង ហើយអោយយកទាំងគោដែលចាប់របស់គេនោះទៅផង ធនញ្ជ័យស្តាប់ហើយឆ្លើយថា បើដូច្នោះឯងជួយដឹកគោអោយអញផង ហើយក៏ដឹកគោទាំងនោះទៅដល់មហាសេដ្ឋី អាបំរើទៅជំរាបថា ចៅជ័យមកដល់ហើយ យកទាំងគោនោះមកផង មហាសេដ្ឋីសួរថា អាជ័យ ឯងដូចម្តេចក៏បានជាទៅចាប់គោគេហើយថាលួចប្រពន្ធអាឯង ឯធនញ្ជ័យជំរាបថា ខ្ញុំបាទបានជំរាបសូមយកគោញីនោះឯងជាប្រពន្ធខ្ញុំបាទ ឥឡូវគោឈ្មោលទាំងអស់នោះវាដេញចង់ប្រពន្ធរបស់ខ្ញុំបាទ បានជាខ្ញុំបាទចាប់ចងទុកនឹងយកមកប្តឹងលោកតា បើលោកតាមានប្រសាសន៍ដូចម្តេចក៏ខ្ញុំបាទព្រម មិនហ៊ានទទឹងទេ។ លុះមហាសេដ្ឋីស្តាប់ធនញ្ជ័យជំរាបដូច្នោះហើយក៏ប្រាប់ថា អាឯងអោយគោរបស់គេទៅម្ចាស់គេវិញ ហើយខ្លួនអាឯងកុំទៅឃ្វាលគោទៀត វាបង្កើតទោសច្រើនណាស់ អាឯងបានតែប្រើការក្នុងផ្ទះវិញទើបជា។ ធនញ្ជ័យក៏ខានពុំបានទៅឃ្វាលគោអំពីថ្ងៃនោះឯង មហាសេដ្ឋីប្រើធនញ្ជ័យអោយធ្វើការក្នុងផ្ទះតែសព្វថ្ងៃទៅ។

មានកាលថ្ងៃមួយ មហាសេដ្ឋីចេញទៅអង្គុយលេងនៅសាលាក្រៅនិយាយនឹងអស់នាម៉ឺនមន្ត្រីដែលគេមកគិតការអ្វីៗនឹងមហាសេដ្ឋី អំពីព្រឹកដល់ថ្ងៃត្រង់ ពេលឃ្លានបាយ ប្រពន្ធមហាសេដ្ឋីស្រដីប្រើថា អាជ័យ ទៅហៅលោតាអាឯងមកពិសាបាយ វាថ្ងៃណាស់ហើយ។ ធនញ្ជ័យស្តាប់ហើយក៏ដើរទៅហៅមហាសេដ្ឋីថា លោកតាអើយពិសាបាយ ដើរបន្តិចទៅស្រែកហៅម្តងទៅ ឮដល់មហាសេដ្ឋី មហាសេដ្ឋីក៏ខ្មាសគេណាស់ តែមិនស្រដីថាអោយដឹងឡើយ។ លុះធនញ្ជ័យទៅដល់ហើយ ចូលទៅរកមហាសេដ្ឋីស្រែកថា លោកយាយអោយហៅលោកតាទៅពិសាបាយ ត្បិតថ្ងៃណាស់ហើយ មហាសេដ្ឋីខឹងណាស់ ចុះពីលើសាលាដើរទៅដល់ផ្ទះទើបស្រដីថា ដូចម្តេចក៏បានអាជ័យឯងស្រែកហៅអញខ្លាំងៗម៉្លេះ បើដើរដល់ជិតសឹមប្រាប់វាអ្វី ធនញ្ជ័យឆ្លើយថា ខ្ញុំបាទនឹងធ្វើឯងក៏ទេ ត្បិតលោកយាយប្រើអោយហៅលោកតាមកពិសាបាយ បានជាខ្ញុំបាទហៅដូច្នោះឯង

មហាសេដ្ឋីស្រដីថា អាឯងអំពីថ្ងៃនេះទៅ បើគេប្រើអោយទៅហៅអញ អាឯងដើរ ដើរអោយដល់សិនទៅសឹមប្រាប់អញតិចៗ កុំអោយគេឮឡើយ បើអាឯងហៅអញ ដូចពីមុននេះទៀត អញវាយអាឯងមិនខាន ធនញ្ជ័យស្តាប់ហើយក៏ចាំទុកក្នុងចិត្ត។

នៅយូរបន្តិចទៅ មានកាលមួយថ្ងៃ មហាសេដ្ឋីដើរទៅអង្គុយឯសាលា ក្រោបង្គាប់មនុស្សម្នាអោយធ្វើការ គ្រានោះភ្លើងឆេះផ្ទះមហាសេដ្ឋីនោះឯង ប្រពន្ធមហាសេដ្ឋីភ័យហើយហៅថា អាជ័យទៅហៅលោកតាអាឯង ប្រាប់ថាភ្លើងឆេះផ្ទះអស់ហើយ ឯធនញ្ជ័យក៏ដើរទៅហៅមហាសេដ្ឋីថា លោកតាអើយភ្លើងឆេះផ្ទះអស់ហើយ តែហៅតិចៗ ជើងប្រឹងតែដើរមាត់ក៏ប្រាប់តិចៗថា លោកតាអើយភ្លើងឆេះផ្ទះអស់ហើយ មហាសេដ្ឋីក្រលេកមើលមកឃើញធនញ្ជ័យដើរធ្វើមាត់ម្ហុបៗ មហាសេដ្ឋីមន្ទិលក្នុងចិត្តក៏ស្រែកសួរថា អាជ័យអើយ អាឯងថាអ្វីក៏មិនថាអោយខ្លាំងមក អញនឹងឮ ឯធនញ្ជ័យក៏ថាតិចៗដូចដែលនោះឯង លុះដើរទៅដល់ជិតទើបអោនទៅខ្សឹបថា លោកតា ភ្លើងឆេះផ្ទះអស់ហើយ ឯមហាសេដ្ឋីស្តាប់ដឹងដូច្នោះហើយប្រើថា អាជ័យ ទៅយករបស់ស្រាលៗអោយឆាប់ទៅ ធនញ្ជ័យក៏រត់ទៅយកសំបុកមាន់ដែលវាពុំទាន់បានភ្លើងឆេះ យកទៅទុកជាច្រើនប្រមាណជា ៣០សំបុកមាន់ លុះដល់ភ្លើងរលត់អស់ហើយមហាសេដ្ឋីស្រដីអោយគេយកអស់របស់ដែលយកបានទាន់ពេលភ្លើងពុំបានឆេះនោះមកទាំងអស់ បាត់តែធនញ្ជ័យពុំឃើញយកអ្វីចេញមកនឹងគេ មហាសេដ្ឋីក៏សួរថា អាជ័យឯងយកបានរបស់អ្វីទុកខ្លះ យកមកអោយអញនឹងមើល ធនញ្ជ័យ ថាខ្ញុំបាទយកបានច្រើនណាស់ ចាំខ្ញុំបាទទៅយកមកជូន ហើយធនញ្ជ័យទៅយកសំបុកមាន់ទាំងនោះមកអោយមហាសេដ្ឋី ឯមហាសេដ្ឋីថា អាជ័យ ដូចម្តេចក៏ទៅយកសំបុកមាន់ទៅវិញ ឯរបស់ឯទៀតក៏អាឯងមិនយក ធនញ្ជ័យឆ្លើយថា ត្បិតលោកតាផ្តាំថាអោយយករបស់ស្រាលៗនោះឯង បានជាខ្ញុំបាទយកសំបុកមាន់ព្រោះវាស្រាលជាងរបស់ដទៃ។ ពេលមហាសេដ្ឋីសួររកមុខអ្នកដើមភ្លើងដែលធ្វើអោយឆេះផ្ទះ ធនញ្ជ័យក៏ស្ទុះទៅ

ចាប់ដើងក្រានចងដាក់ឃ្នាងនាំយកមកជូនមហាសេដ្ឋីហើយស្រដីជំរាបថា ដើង ក្រាននេះឯងជាដើមភ្លើង ភ្លើងតែងតែនាំឆេះអំពីដើងក្រាននេះឯង រាល់ផ្ទះ មនុស្សសព្វថ្ងៃប្រាកដជាឆេះចេញពីដើងក្រានមិនខាន ថាបើមិនមែនទេ ខ្ញុំបាទ ទទួលខុសអោយលោកតាធ្វើទោស។ ឯមហាសេដ្ឋីស្តាប់ហើយក៏គិតតែក្នុងចិត្តថា អាជ័យនេះឃើញថាអញប្រើវាមិនបាន បើប្រើទៅឃើញថានឹងខូចអស់ទ្រព្យច្រើន បើដូច្នោះមានតែអញនាំទៅថ្វាយស្តេចអោយស្រលះពីខ្លួនអញ គិតដូច្នោះហើយ គាត់ក៏ប្រាប់ថា អាជ័យ អញនឹងឯងយកទៅថ្វាយហ្លួងក្នុងព្រឹកស្អែកនេះឯងហើយ ឯធនញ្ជ័យក៏នៅស្ងៀម។

លុះព្រឹកឡើង មហាសេដ្ឋីក៏រៀបចំខ្លួនឡើងទៅគាល់ស្តេច ហើយយក ធនញ្ជ័យទៅជាមួយផង ទៅដល់ហើយក្រាបបង្គំគាល់ទើបទូលថា សូមទានក្រាប ទូល ត្បិតទូលបង្គំជាខ្ញុំមានក្មេងម្នាក់មានប្រាជ្ញាណាស់ នឹងដេញប្រាជ្ញាវាមិនទាន់ ឡើយ គ្មានមនុស្សឯណានឹងកុហកដូចគ្នាន ឥឡូវនេះទូលបង្គំជាខ្ញុំយកមកថ្វាយ ជាខ្ញុំហ្លួងធូលីព្រះបាទ ឯព្រះមហាក្សត្រទ្រង់សណ្តាប់ហើយមានបន្ទូលត្រាស់ ហៅថា អាជ័យចូលមកអាយ ធនញ្ជ័យក៏ឆ្លើយថា ព្រះករុណាថ្លៃវិសេស ហើយ ខិតចូលទៅជិតមុខព្រះភក្ត្រ ទើបមហាក្សត្រសួរថា អាជ័យឯងចេះកុហកមែនឬ? ធនញ្ជ័យក៏ក្រាបទូលថា ចេះមែន។ ស្តេចត្រាស់ថា បើដូច្នោះអាឯងកុហកមក អញនឹងមើល ធនញ្ជ័យក្រាបទូលថា ឯកុហកនេះមានក្បួននៅផ្ទះទូលបង្គំជាខ្ញុំ ទើបស្តេចត្រាស់ថា បើដូច្នោះអាឯងទៅយកមកនឹងកុហកអោយអញមើល។ ធនញ្ជ័យក្រាបទូលថា មានតែអោយអ្នកណាម្នាក់ទៅយកក្បួនអំពីផ្ទះទូលបង្គំ ជាខ្ញុំ ទើបស្តេចត្រាស់ប្រើមហាតលិកម្នាក់ថា អាឯងទៅយកក្បួនកុហកពីផ្ទះ អាជ័យមកអោយឆាប់ ឯមហាតលិកនោះក្រាបថ្វាយបង្គំ ហើយក៏រត់ទៅផ្ទះ ធនញ្ជ័យ ប្រាប់ម្តាយធនញ្ជ័យថា ត្បិតធនញ្ជ័យប្រាប់ថាអោយមកយកក្បួន កុហក ឯម្តាយស្តាប់ហើយឆ្លើយប្រាប់ថាគ្មានទេ។ មហាតលិកវិលទៅវាំង

វិញទូលស្តេចតាមដំណើរ ទើបស្តេចមានព្រះបន្ទូលត្រាស់សួរថា អាជ័យអាឯង ថាមានក្បួនកុហកនៅឯផ្ទះ ឥឡូវនេះអោយទៅយក ម្តាយឯងថាគ្មានទេ ធនញ្ជ័យ ក៏ក្រាបទូលថា នេះហៅថាកុហកថ្វាយហើយ សូមទានជ្រាប។ ស្តេចស្តាប់ហើយ ក៏ទ្រង់ព្រះសំរួល មានព្រះបន្ទូលថា អាជ័យឯងនៅគាល់បំរើអញសព្វៗថ្ងៃកុំអោយ ខាន ឯធនញ្ជ័យទទួលព្រះបន្ទូលហើយក៏នៅស្ងៀម ហើយគាល់បំរើគ្មានខានដល់ មួយថ្ងៃ។

មានកាលមួយថ្ងៃ ស្តេចគិតក្នុងព្រះរាជហឫទ័យថា អញនឹងល្បងប្រាជ្ញា អាជ័យចង់ដឹងមើល លុះដល់ព្រឹកឡើងស្តេចយាងទៅកំពង់ទឹក ហើយបានហៅ អស់ទាំងនាម៉ឺនតូចធំទាំងប៉ុន្មានអោយរកពងមាន់មួយម្នាក់មកក្តាប់ក្នុងដៃ ពេលចុះ ក្នុងទឹកមុជទៅងើបឡើងអោយស្រែកថា តុក្កតតពង១ ថ្វាយស្តេច ឯធនញ្ជ័យកុំ អោយដឹងរឿងនេះឡើយ។ អស់នាម៉ឺនមន្ត្រីរកពងបានមួយៗ ហើយម្នាក់ៗមុជចុះ ទឹក ងើបឡើងស្រែកដូចៗគ្នាថា តុក្កតតពងមួយ យកពងទៅថ្វាយស្តេចគ្រប់តែ គ្នាអស់ហើយនៅសល់តែធនញ្ជ័យក្រោយគេ មិនបានដឹងខ្លួនថាស្តេចអោយចុះ ទឹកកាន់ពងមាន់ទៅដូច្នោះឡើយ លុះស្តេចអោយហៅមកថា អាជ័យឯងចុះមុជ ទឹកទៅងើបឡើងនឹងអាលថ្វាយពងមាន់មួយដូចគេ ធនញ្ជ័យនឹងរកពងមាន់គ្មាន តែមុជចុះទឹកដូចគេដែរ ពេលងើបឡើងស្រែកថា កឹគគិគលគក ឯស្តេចមានបន្ទូល សួរថា ឯណាអាជ័យពងមាន់ ទើបធនញ្ជ័យទូលថា ទូលបង្គំនេះជាមាន់ឈ្មោល ជាន់មាន់ញីទាំងអស់នេះឯង បានជាមានពង បើកុំតែទូលបង្គំជាមាន់ឈ្មោល ហើយជាន់មាន់ញីទាំងនេះ មេមាន់ទាំងនេះគ្មានពងទេក្រាបទូល សូមទ្រង់ជ្រាប។ ស្តេចស្តាប់ហើយក៏កោតប្រាជ្ញាធនញ្ជ័យហើយមានព្រះបន្ទូលសួរថា អាជ័យអាយុ ឯងប៉ុន្មានឆ្នាំហើយ ធនញ្ជ័យក្រាបទូលថា អាយុទូលបង្គំខ្ញុំបាន១១ឆ្នាំ។ ស្តេចស្តាប់ហើយមានព្រះបន្ទូលប្រាប់អស់នាម៉ឺនអោយបានដឹងថា ត្បិតស្តេចនឹង យាងទៅប្រពាតព្រៃ អោយអស់នាម៉ឺនរៀបចំខ្លួនចាំកំណត់ដប់ថ្ងៃទៀតទើបស្តេច

យាងទៅ ឯអស់នាម៉ឺនបានស្ដាប់ព្រះបន្ទូលដូច្នេះហើយក៏រៀបខ្លួនគ្រប់តាមមុខងាររៀងខ្លួន លុះដល់កំណត់ថ្ងៃចេញទៅហើយ ទើបស្ដេចហៅធនញ្ជ័យមកមានបន្ទូលបង្គាប់ថា អាជ័យឯង អញអោយជិះដំរីដែលដាក់ក្រយាស្ងោយទៅអោយបានទាន់អញ បើមិនទាន់អញ ឯងនឹងមានសេចក្ដីខុសមិនលែងឡើយ ឯដំរីនោះស្ដេចអោយយកដំរីចាស់នឹងដើរមិនចង់រួច ហើយអោយធនញ្ជ័យជិះទៅ ធនញ្ជ័យក៏ឡើងជិះបរទៅ ដំរីវាដើរមិនទាន់គេឡើយ ធនញ្ជ័យក៏ធ្វើក្ដាំងហើយយកថ្នោលដោលលើខ្នងដំរីនោះឯង។ ព្រះមហាក្សត្រស្ដេចយាងទៅដល់ព្រះពន្លា ហើយអោយរកធនញ្ជ័យក៏បាត់ ហើយត្រាស់ថា អាជ័យនេះខុសមិនខានហើយ លុះដល់យូរទើបធនញ្ជ័យមកដល់ ព្រះមហាក្សត្រអោយហៅធនញ្ជ័យមកសួរថា អាជ័យឯងបរដំរីដូចម្ដេចក៏មិនទាន់អញ អាឯងខុសហើយ ត្បិតអញបានប្រាប់ថាអោយមកអោយទាន់កុំខាន ធនញ្ជ័យស្ដាប់ព្រះបន្ទូលហើយក៏ក្រាបទូលថាត្បិតដំរីវាមិនដើរ ទូលព្រះបង្គំជាខ្ញុំធ្វើក្ដាំងបើក ហើយធ្វើថ្នោលដោលផង ទូលព្រះបង្គំជាខ្ញុំនឹងបានប្រហែសក៏ទេ សូមទ្រង់ជ្រាប។ ស្ដេចស្ដាប់ហើយក៏ស្ងៀមនៅ នឹងមានបន្ទូលថាដូចម្ដេចក៏ទេ។ ស្ដេចក្រសាលសប្បាយទៅ លុះដល់ថ្ងៃរសៀលវិលមកវិញហើយចូលផ្ទំ ស្ដេចគិតក្នុងព្រះរាជហឫទ័យថា អាជ័យនេះមានប្រាជ្ញាណាស់ នឹងគិតធ្វើដូចម្ដេចអោយទាល់ប្រាជ្ញាវានោះ បើដូច្នោះមានតែអញនឹងដេញប្រាជ្ញាវាទៀត ស្ដេចទ្រង់ព្រះតំរិះដូច្នេះហើយ អោយអស់នាម៉ឺនមុខមន្ត្រី នូវអស់មហាតលិកនូវអស់ឃុនម៉ឺនក្នុងងារដែលមាននៅក្នុងព្រះនគរអោយមកជួបជុំនឹងទ្រង់បង្គាប់អោយហែរស្ដេចចេញទៅប្រពាតព្រៃទៀតនៅថ្ងៃស្អែកនេះឯង តែអោយជិះសេះហែរអោយបានគ្រប់គ្នា តែអ្នកណាគ្មានសេះជិះនឹងបានសេចក្ដីខុសមិនលែងឡើយ ឯធនញ្ជ័យកុំអោយវាដឹងសេចក្ដីនេះ បើព្រឹកឡើងនឹងចេញទៅហើយសឹមប្រាប់អាជ័យថា អោយរកសេះជិះទៅ។ លុះដល់ព្រឹកឡើងស្ដេចចេញដំណើរទៅ អស់នាម៉ឺនឡើងជិះសេះហែរស្ដេច ឯព្រះមហាក្សត្រ

អោយហៅធនញ្ជ័យមកហើយទ្រង់បង្គាប់ថា អាជ័យឯងមកហែរអញទៅ ហើយអោយរកសេះជិះ ដើរទៅដើងទទេអញនឹងយកទោសអាឯងថាខុស ឯធនញ្ជ័យស្តាប់ហើយទទួលព្រះបន្ទូល រត់រកសេះគ្មាន ឥតនរណានឹងអោយ។ ព្រះមហាក្សត្រប្រាប់ធនញ្ជ័យហើយស្តេចយាងចេញទៅ ឯធនញ្ជ័យកាលរកសេះមិនបានក៏រត់ទៅយកសេះកូនចត្រង្គក្តាប់នឹងដៃ ហើយដើរទៅហែរស្តេច។ ព្រះមហាក្សត្រស្តេចទៅដល់ព្រះពន្ធាហើយរកធនញ្ជ័យមិនឃើញ។ ធនញ្ជ័យដើរអំពីចំងាយលុះដល់ល្មមស្តេចទតមកឃើញក៏ប្រឹងរត់ទៅដល់ ហើយក្រាបថ្វាយបង្គំ ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលសួរថា អាជ័យអញអោយឯងជិះសេះមក ឥឡូវនេះម្តេចក៏មិនជិះសេះ ធនញ្ជ័យលាបាតដៃហើយក្រាបទូលថា សេះនេះដែលទូលបង្គំជាខ្ញុំជិះហែរម្ចាស់ ស្តេចស្តាប់ហើយក៏ស្ងៀមនៅ មិនមានព្រះបន្ទូលជាអ្វីឡើយ ហើយស្តេចក៏វិលមកក្នុងព្រះរាជវាំងវិញ។

ព្រឹកមួយស្តេចត្រាស់ហៅអោយធនញ្ជ័យមកគាល់ហើយមានព្រះបន្ទូលថា អាជ័យឯងទៅបោសក្រោមដំណាក់កុំអោយមានសំរាមនៅក្រោមដំណាក់អស់អ្នកម្នាងសព្វៗថ្ងៃទៅ បើអាឯងខាននឹងបានសេចក្តីខុសមិនលែងឡើយ ធនញ្ជ័យស្តាប់ព្រះបន្ទូលហើយក៏រៀបខ្លួនចូលទៅបោសក្រោមដំណាក់អស់អ្នកម្នាងនោះ។ អស់ទាំងស្ត្រីបំរើវាដើរទន្ទ្រាំលើក្បាលធនញ្ជ័យតែសព្វៗថ្ងៃ ឯធនញ្ជ័យគិតថាអស់ទាំងស្ត្រីនេះដើរលើក្បាលអញ បើដូច្នោះអញនឹងគិតធ្វើកុំអោយស្តេចប្រើមកបោសក្រោមដំណាក់នេះទៀតបានឡើយ។ គិតស្រេចហើយធនញ្ជ័យក៏ស្រែកជេរថា មេចោរជកទង់ទាំងអស់នេះ វាបានស៊ីក៏តែពីគូទ វាមិនបានស៊ីក៏តែពីគូទវា។ ធនញ្ជ័យស្រែកជេរខ្លាំងៗឮដល់អស់អ្នកម្នាងនៅខាងលើដំណាក់នោះ ពួកអ្នកម្នាងខឹងនឹងធនញ្ជ័យក៏បបួលគ្នាឡើងទៅក្រាបទូលស្តេចថា សូមទ្រង់ជ្រាប ត្បិតទ្រង់ត្រាស់ប្រើអាជ័យអោយវាទៅបោសក្រោមដំណាក់ ឥឡូវនេះវាជេរបញ្ចោរអស់ទាំងយើងខ្ញុំជាទំងន់ មុខគួរអោយខ្មាសអស់មនុស្សផងទាំងពួង នឹងធ្វើជាព្រះម្នាងស្តេច

មិនបានទេ សូមជ្រាប។ ព្រះមហាក្សត្រមានបន្ទូលសួរថា វាដេរដូចម្តេច ទើបអ្នកម្នាងទូលថា ដេរមេចោរដកទងទាំងអស់នេះ វាបានស៊ីតែពីគូទ វាមិនបាន ស៊ីក៏តែពីគូទវា។ ស្តេចស្តាប់ហើយក៏ទ្រង់ព្រះក្រោធ ត្រាស់អោយហៅធនញ្ជ័យ មកហើយមានបន្ទូលសួរថា អាជ័យឯងអញប្រើអោយឯងទៅបោសក្រោមដំណាក់ ដូចម្តេចក៏បានអាជ័យឯងដេរបញ្ចោរប្រពន្ធអញមែនឬទេ ទើបធនញ្ជ័យក្រាបទូល ថា ទូលបង្គំជាខ្ញុំនឹងបានដេរបញ្ចោរអស់អ្នកម្នាងក៏ទេ ប៉ុន្តែកាលទូលបង្គំចូលទៅ បោសក្រោមដំណាក់នោះមានពីងពាងព័ទ្ធក្រោមដំណាក់យ៉ាងច្រើន ដល់ទូលបង្គំ ចូលទៅបោសវាជាប់ក្បាលទូលព្រះបង្គំជាខ្ញុំ បានជាដេរថាមេចោរដកទង វាបានស៊ី តែពីគូទ វាមិនបានស៊ីក៏តែពីគូទវា ព្រោះពីពាងវាធ្វើសំបុកនឹងគូទចាំចាប់សត្វដទៃ ស៊ីជាអាហារ ទូលបង្គំជាខ្ញុំនឹងបានដេរអស់អ្នកម្នាងជាម្ចាស់ក៏ទេ សូមទ្រង់ជ្រាប។ ព្រះមហាក្សត្រស្តាប់ហើយក៏មានបន្ទូលនឹងអស់អ្នកម្នាងថា អស់ឯងកុំខឹងនឹងវា អាជ័យវានឹងបានដេរឯងក៏ទេ វាដេរតែពីងពាងទេ ទើបអស់អ្នកម្នាងក្រាបទូលថា អំពីថ្ងៃនេះទៅម្ចាស់កុំអោយអាជ័យវាទៅបោសក្រោមដំណាក់នោះទៀតឡើយ។ ព្រះមហាក្សត្រក៏ហាមធនញ្ជ័យមិនអោយទៅបោសក្រោមដំណាក់នោះទៀត ឯ ធនញ្ជ័យក៏ខានពុំបានចូលបោសក្រោមដំណាក់អំពីថ្ងៃនោះឯង។

ព្រះមហាក្សត្រគិតក្នុងព្រះហឫទ័យថា អាជ័យនេះជាមានប្រាជ្ញាណាស់ នឹងដេញប្រាជ្ញាវាមិនទាន់ បើដូច្នេះអញនឹងអោយវាយកមាន់មកជល់នឹងមាន់ អញម្តង ហើយអញនឹងអោយហាមប្រាមអ្នកនគរអញកុំអោយនរណាអោយមាន់ ខ្លាំងប្រជល់មកធនញ្ជ័យទោះទិញក្តីឬខ្ចីក្តី បើនរណាអោយខ្ចីឬលក់អោយធនញ្ជ័យ នឹងយកទោសខុសមិនខានឡើយ គិតក្នុងព្រះហឫទ័យដូច្នោះហើយស្តេចក៏ ក្រសាលសប្បាយទៅ។ លុះដល់ព្រឹកឡើយស្តេចចេញមកគង់នៅសាលាក្រៅ ទ្រង់អោយហៅនាម៉ឺនមកជួបជុំ ហើយមានព្រះបន្ទូលបង្គាប់អោយរកមាន់មកជល់ នៅមុខព្រះលាន ហើយអោយហៅធនញ្ជ័យមកគាល់ផង លុះធនញ្ជ័យមកដល់

ស្តេចមានព្រះបន្ទូលបង្គាប់ថា អាជ័យឯងទៅយកមាន់អាឯងមកជល់នឹងមាន់អញអោយបានឥឡូវនេះឯង ឯធនញ្ជ័យក៏ក្រាបបង្គំលាទៅរកមាន់ហើយគិតថា ព្រះមហាក្សត្រនឹងផ្ចាញ់ប្រាជ្ញាអញទៀតហើយ បើអញនឹងរកទិញមាន់គេ លោកមុខតែហាមប្រាមមិនអោយនរណាលក់អោយឡើយ បើដូច្នោះងាយទេ អញនឹងយកមាន់អញនេះឯង គង់តែនឹងជល់ឈ្នះមាន់របស់ព្រះមហាក្សត្រមិនខានឡើយ។ គិតហើយធនញ្ជ័យក៏ដើរដល់ផ្ទះខ្លួនហើយចាប់យកកូនមាន់ដែលទើបនឹងញាស់ហើយយកសំពត់រុំកូនមាន់នោះរួចដើរទៅ លុះដល់ព្រះមហាក្សត្រហើយក្រាបថ្វាយបង្គំ ស្តេចទតមើលមិនឃើញធនញ្ជ័យយកមាន់មកជល់តាមទ្រង់បង្គាប់ក៏ទ្រង់មានព្រះបន្ទូលសួរថា អាជ័យឯណាមាន់ដែលអាឯងត្រូវយកមកជល់នឹងមាន់អញនោះ ឯធនញ្ជ័យក៏ក្រាបទូលថា អោយតែយកមាន់ព្រះរាជទ្រព្យនោះមកនឹងជល់នឹងមាន់របស់ទូលព្រះបង្គំជាខ្ញុំ ទើបព្រះមហាក្សត្រត្រាស់ប្រើអោយទៅយកមាន់ព្រះរាជទ្រព្យមកជល់ ហើយអោយលែងមាន់នោះនៅទីប្រជល់នោះឯង។ ឯអស់នាម៉ឺនក៏ដាក់មាន់អោយជល់គ្នាដោយគូៗគ្រប់គ្នា ឯព្រះមហាក្សត្រមានព្រះបន្ទូលតឿនទៅថា អាជ័យថ្វីក៏មិនលែងមាន់អាឯងទៅមើល ធនញ្ជ័យឮព្រះបន្ទូលតឿនដូច្នោះហើយក៏យកកូនមាន់ដែលរុំនឹងសំពត់សដាក់ទៅអោយជល់នឹងមាន់ព្រះរាជទ្រព្យ ឯកូនមាន់នោះកាលបើឃើញមាន់ធំ វាស្មានថាជាមេវាក៏រត់ទៅសសុលក្រោមពោះមាន់ធំនោះ ឯមាន់ធំកាលបើឃើញកូនមាន់រត់មកសសុលក្រោមពោះដូច្នោះ វាក៏រត់ចេញ ធនញ្ជ័យក៏ទះដៃស្រែកថា មាន់ធំនោះចាញ់មាន់អញហើយ មិនហ៊ានជល់ទេ វារត់ទៅហើយ។ ឯព្រះមហាក្សត្រក៏ទ្រង់ព្រះក្រោធនឹងធនញ្ជ័យហើយវិលចូលទៅក្នុងព្រះរាជមន្ទីរ ហើយទ្រង់ព្រះចិន្តាថា បើដូច្នោះអញនឹងប្រជល់ក្របីវិញ។

មានកាលមួយថ្ងៃ ស្តេចត្រាស់ហៅអស់នាម៉ឺនមកហើយមានព្រះបន្ទូលហាមអស់នាម៉ឺនថា បើអាជ័យវារកខ្ចីក្របីនរណា កុំអោយរាស្ត្រណាអោយឡើយ

បើនរណាអោយខ្ញុំនឹងមានទោសខុស ទ្រង់ហាមអស់នាម៉ឺនស្រេចហើយក៏យាង ក្នុងដំណាក់វិញ ឯធនញ្ជ័យនឹងបានដឹងថាស្ដេចហាមដូច្នេះក៏ទេ។ លុះព្រឹកឡើង ស្ដេចចេញមកគង់នៅសាលាក្រៅហើយប្រើអោយយកក្របីព្រះរាជទ្រព្យ១ដែល ឡើងកំលាំងមកដល់ ឥតមានក្របីឯណានឹងជល់បានឡើយ។ ក្របីព្រះរាជទ្រព្យ មកដល់ហើយ ស្ដេចមានព្រះបន្ទូលអោយបំរើទៅហៅធនញ្ជ័យអោយក្របីមក ប្រជល់នឹងក្របីព្រះរាជទ្រព្យកុំអោយខានឡើយ។ បំរើស្ដាប់ហើយក៏រត់ទៅប្រាប់ ធនញ្ជ័យដូចមានព្រះបន្ទូលបង្គាប់នោះឯង ធនញ្ជ័យស្ដាប់ព្រះបន្ទូលដូច្នោះហើយ ក៏ចុះអំពីផ្ទះទៅចាប់យកកូនក្របីដែលទើបសំរាលបានដប់ថ្ងៃហើយចងកូនក្របី នោះដឹកនាំជាមួយនឹងបំរើទៅដល់ ហើយក្រាបថ្វាយបង្គំគាល់ ឯព្រះមហាក្សត្រ ស្ដេចទតមកឃើញក្របីដែលធនញ្ជ័យដឹកមកដល់ ក៏ទ្រង់បង្គាប់ធនញ្ជ័យថា អោយ យកក្របីអាឯងមកជល់នឹងក្របីអញមើល ទើបធនញ្ជ័យដឹកកូនក្របីទៅទៀបក្របី ធំនោះឯង ឯកូនក្របីវាមើលទៅឃើញក្របីធំនោះហើយ វាស្មានថាជាមេវា វាក៏ រត់ទៅបៅពងបោ្លកក្របីធំនោះ ឯក្របីធំវារសើប វាក៏ស្ទុះបោលដាច់ខ្សែនឹងចាប់ក៏ មិនបាន ធនញ្ជ័យស្រែកថា ចាញ់ហើយៗ កូនក្របីក៏ប្រឹងបោលតាមក្របី ឈ្មោលនោះឯង ព្រោះវាថាជាមេរបស់វា។ ឯព្រះមហាក្សត្រទតទៅឃើញក្របី ព្រះរាជទ្រព្យនោះវាបោលទៅ ហើយឃើញកូនក្របីវាបោលតាមពីក្រោយដូច្នោះ ក៏អៀនក្នុងព្រះហឫទ័យណាស់ ហើយស្ដេចមានព្រះបន្ទូលប្រាប់អស់នាម៉ឺន អោយឃាត់ធនញ្ជ័យកុំអោយចូលក្នុងរាជវាំងឡើយ បើនរណាអោយអាជ័យវា ចូលក្នុងវាំង អញនឹងយកទោសខុសមិនលែងឡើយ។ មានព្រះបន្ទូលដូច្នេះហើយ ស្ដេចយាងចូលទៅក្នុងដំណាក់វិញ ឯអស់នាម៉ឺនហៅធនញ្ជ័យមកប្រាប់ថា ត្បិត ស្ដេចទ្រង់បង្គាប់អោយប្រាប់អាជ័យឯងថា ពីថ្ងៃនេះទៅដល់១០ឆ្នាំ កុំអោយចូល ក្នុងព្រះរាជវាំងទៀត បើឯងមិនស្ដាប់ ឯងនឹងមានសេចក្ដីខុសមិនខានឡើយ។ ឯធនញ្ជ័យស្ដាប់ហើយក៏ស្ងៀមនៅ ហើយលាចេញដើរទៅផ្ទះអាត្មាវិញ។

លុះយូរប្រមាណបានបួនថ្ងៃនឹងដល់ថ្ងៃសីល ស្តេចនឹងនិមន្តលោកគ្រូសង្ក្រាជចូលទៅទេសនាក្នុងរាជវាំង ធនញ្ជ័យដឹងដូច្នេះហើយក៏ដើរទៅអង្គុយក្នុងសាលាក្រៅ ជួបនឹងនាម៉ឺនមុខមន្ត្រីតូចធំជុំគ្នាច្រើន ហើយធនញ្ជ័យធ្វើជាស្រដីថាក្នុងថ្ងៃសីលនេះ ស្តេចនឹងហៅខ្ញុំទៅក្នុងវាំងមិនខានឡើយ ឯអស់នាម៉ឺនបានឮធនញ្ជ័យថាដូច្នោះហើយក៏សើចទាំងអស់គ្នាហើយថា ហ្អែអាជ័យគេចូលទៅបានមែនហើយ ថាដូច្នោះហើយក៏ចុះដើរទៅផ្ទះទីទៃៗ ឯធនញ្ជ័យក៏ដើរទៅផ្ទះវិញៗ លុះដល់ព្រឹកថ្ងៃសីល ស្តេចអោយទៅនិមន្តលោកគ្រូសង្ក្រាជចូលទៅទេសនាក្នុងព្រះរាជវាំង ឯធនញ្ជ័យក៏ទៅអង្គុយចាំផ្លូវលោកគ្រូសង្ក្រាជ លោកគ្រូសង្ក្រាជក៏ដើរតាមផ្លូវទៅជួបនឹងធនញ្ជ័យ ឯធនញ្ជ័យមើលឃើញលោកគ្រូសង្ក្រាជដើរមកដល់ហើយក្រាបថ្វាយបង្គំទូលថា សូមលោកគ្រូមេត្តាឈប់សិន ត្បិតខ្ញុំកុណាដឹងការណ៍មួយជាមន្ទិល ខ្ញុំកុណានឹងទូលអោយជ្រាប លោកគ្រូសង្ក្រាជស្តាប់ហើយក៏ឈប់នៅ ឯធនញ្ជ័យក៏ដើរចូលទៅជិតទូលថា មើលសក់ក្បាលខ្ញុំដូចសក់ក្ងោកមើលទៅមុខលោកគ្រូគ្រាន់ជាងគូទខ្ញុំ ឯលោកគ្រូសង្ក្រាជស្តាប់ហើយខ្ទាល់នឹងធនញ្ជ័យដៀលមុខដូច្នោះលោកគិតថា អញនឹងទៅទូលព្រះមហាក្សត្រ លុះទៅដល់ជួបនឹងស្តេចហើយ លោកគ្រូសង្ក្រាជថ្វាយព្រះពរទូលថា ត្បិតអាជ័យវាស្រដីអោយអាត្មាភាពថា មើលទៅសក់វាដូចសក់ក្ងោក មើលមកមុខអាត្មាភាពគ្រាន់ជាងគូទវា សូមព្រះមហារាជយកធនញ្ជ័យមកជំនុំជំរះអោយអាត្មាភាពសុខចិត្តផងទើបបាន កុំអោយអាជ័យវាស្រដីអោយអាត្មាភាពដូច្នេះទៀត។ ព្រះមហាក្សត្រស្តាប់ពុទ្ធដីកាលោកគ្រូសង្ក្រាជដូច្នោះហើយ ស្តេចត្រាស់ប្រើមហាតលិកម្នាក់អោយទៅហៅធនញ្ជ័យអោយចូលគាល់ស្តេចអោយឆាប់ កុំយូរឡើយៗ ឯចៅធនញ្ជ័យស្រដីអោយលោកដូច្នោះហើយ ក៏ទៅអង្គុយនៅសាលាក្រៅជាមួយអស់នាម៉ឺន ហើយថាបន្តិចទៀតស្តេចនឹងអោយមកហៅខ្ញុំចូលទៅគាល់មិនខានកាលណាឮធនញ្ជ័យស្រដីដូច្នោះហើយ នាម៉ឺនអស់នោះស្រដីចំអកថា មែនហើយ

បន្តិចគេចូលទៅគាល់ហ្លួងមិនខានឡើយ ឯមហាតលិកនោះ កាលបើដើរទៅដល់មុខសាលាឃើញធនញ្ជ័យក៏ប្រាប់ថា ត្បិតព្រះករុណាមានព្រះបន្ទូលអោយហៅអាជ័យឯងទៅចូលគាល់ឥឡូវនេះកុំខាន ធនញ្ជ័យស្តាប់ហើយក៏ប្រាប់អស់នាម៉ឺនថា ខ្ញុំថាម្ចាស់នឹងអោយហៅចូលវាំងមិនខាន អស់លោកមិនជឿខ្ញុំ ថាហើយធនញ្ជ័យក៏ចុះតាមមហាតលិកចូលទៅក្នុងវាំង ទៅដល់ក្រាបថ្វាយបង្គំហើយស្ងៀមនៅ ឯព្រះមហាក្សត្រទតឃើញធនញ្ជ័យមកដល់ មានព្រះបន្ទូលសួរថា អាជ័យឯងបានស្រដីថាដូចម្តេចអោយលោកសង្រ្គាជមែនឬ ធនញ្ជ័យទូលថា ទូលបង្គំថាមែន តែនឹងជៀលត្មេះលោកក៏ទេ ថានោះជាឧបមាអោយខ្លួនទូលបង្គំទេតើ ត្បិតលោកចូលក្នុងវាំង ឯខ្លួនទូលបង្គំមិនបានចូលបានជាទូលបង្គំថា មើលសក់ក្បាលខ្ញុំដូចសក់ក្អែក មើលទៅមុខលោកគ្រូគ្រាន់ជាងគូទខ្ញុំ។ ព្រះមហាក្សត្រស្តាប់ហើយមានព្រះបន្ទូលនឹងលោកសង្រ្គាជថា លោកកុំខ្ញាល់នឹងអាជ័យឡើយ វាថាជាឧបមាខ្លួនវាទេ ហើយស្តេចបណ្តេញថា អាជ័យឯងកុំចូលមកក្នុងវាំងអញទៀត ធនញ្ជ័យស្តាប់ហើយក៏ថ្វាយបង្គំវិលទៅផ្ទះវិញ។ ស្តេចមានព្រះបន្ទូលបណ្តេញធនញ្ជ័យហើយក៏គិតក្នុងព្រះរាជហឫទ័យថា ឥតអ្នកណាដេញប្រាជ្ញាអាជ័យបាន អញហាមមិនអោយវាចូលវាំង ឥឡូវនេះវាចូលបាន មិនមានទើស ត្បិតប្រាជ្ញាវាមាន។

ក្រោយមក ស្តេចមានព្រះបន្ទូលបង្គាប់ថា អោយអស់ស្រីនៅក្នុងវាំងទៅជុះអាចម៍ដាក់ផ្ទះអាជ័យ បើវាថាដូចម្តេចអោយចាប់យកទោសខុស។ ឯស្រីអ្នកក្នុងវាំងបានឮព្រះបន្ទូលបង្គាប់ដូច្នោះហើយ ក៏បបួលគ្នាទៅជុះអាចម៍ដាក់ផ្ទះធនញ្ជ័យទៅដល់ហើយប្រាប់ធនញ្ជ័យថា ត្បិតម្ចាស់លោកអោយជុះអាចម៍ដាក់ផ្ទះជ័យឯង ឯធនញ្ជ័យស្តាប់ហើយក៏ឆ្លើយថា បើមានព្រះបន្ទូលដូច្នោះហើយ ខ្ញុំមិនហ៊ានឃាត់ទេ តាមចិត្តអស់អ្នកចុះ បើចង់ជុះក៏ជុះចុះ។ អស់អ្នកទាំងនោះស្តាប់ធនញ្ជ័យថាដូច្នោះហើយក៏បបួលគ្នាជុះអាចម៍ដាក់ផ្ទះធនញ្ជ័យតាមព្រះបន្ទូលស្តេចបង្គាប់នោះ ឯធនញ្ជ័យក៏ដើរមើល ហើយបើឃើញមាននោមផង ធនញ្ជ័យវាយអស់ស្រីដែល

ផុះហើយនោមផង  អស់ស្រីទាំងនោះដឹងធនញ្ជ័យវាយដូច្នោះ ក៏រត់ទៅទូលស្តេចអោយទ្រង់ជ្រាប លុះទៅដល់ហើយក្រាបថ្វាយបង្គំទូលថា ត្បិតម្ចាស់ប្រើអោយទៅផុះអាចម៍ដាក់ផ្ទះធនញ្ជ័យ អស់យើងខ្ញុំទៅផុះដាក់តាមព្រះបន្ទូល  ឥឡូវនេះធនញ្ជ័យវាយអស់យើងខ្ញុំ  សូមទ្រង់ជ្រាប។  ព្រះមហាក្សត្រស្តាប់ហើយត្រាស់ថាអោយអស់ទាហានទៅចាប់អាជ័យយកមកនឹងជំនុំ  ឯអស់ទាហានស្តាប់ព្រះបន្ទូលដូច្នោះហើយ  ក៏ទៅចាប់ធនញ្ជ័យតាមរាជបញ្ជា  លុះទៅដល់ផ្ទះធនញ្ជ័យក៏ឡើងទៅលើផ្ទះចាប់ដៃធនញ្ជ័យចង រួចប្រាប់ថាស្តេចមានព្រះបន្ទូលអោយមកចាប់យកឯងទៅ  ព្រោះទ្រង់ខ្ញាល់ណាស់  ឯធនញ្ជ័យស្តាប់ហើយគិតថា បើដូច្នោះអញនឹងធ្វើកុំអោយវាចងអញបាន  គិតស្រេចហើយក៏ថា អស់ទាំងអ្នកឯងនឹងចងអញនេះមិនបានទេ តែអញថាអោយឯងស្ងាប់ ឯងនឹងស្ងាប់មិនខាន ឯងមិនដឹងទេ នេះឯងហើយឈ្មោះធនញ្ជ័យអ្នកប្រាជ្ញ សូវលែងវិញជា អស់ទាហានស្តាប់ពាក្យធនញ្ជ័យហើយក៏មិនហ៊ានចងដៃធនញ្ជ័យ នាំគ្នាស្រាយខ្សែចេញ  ធនញ្ជ័យក៏ដើរដើងទទេទៅដល់ក្រាបថ្វាយបង្គំ នៅស្ងៀមចាំស្តាប់ព្រះបន្ទូល។  ព្រះមហាក្សត្រទតឃើញធនញ្ជ័យមកដល់ហើយ    មានព្រះបន្ទូលបណ្តឹងថា   អាជ័យដូចម្តេចក៏បានជាអាឯងដេញវាយសាវឡឹកដែលអញអោយទៅផុះអាចម៍ដាក់ផ្ទះអាឯងនោះ តើអាឯងខុសឬអាឯងត្រូវ  ទើបធនញ្ជ័យយកសេចក្តីក្រាបទូលថា  បានជាទូលបង្គំជាខ្ញុំវាយនោះ  ត្បិតអស់អ្នកសាវឡឹកធ្វើល្មើសព្រះបន្ទូល  ខុសមិនត្រូវ ត្បិតទ្រង់បង្គាប់ថាអោយទៅតែផុះអាចម៍ទេ នឹងមានព្រះបន្ទូលថាអោយទៅនោមឯណា   ឥឡូវអស់អ្នកទាំងនោះទៅផុះផងនោមផង ហេតុដូច្នោះហើយបានជាទូលបង្គំជាខ្ញុំវាយសូមទ្រង់ជ្រាប។   ព្រះមហាក្សត្រស្តាប់ហើយក៏នៅស្ងៀម  ពុំមានព្រះបន្ទូលថាអ្វីៗឡើយ   នឹងយកទោសធនញ្ជ័យក៏មិនបាន។